# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*ពួកនេះវាឃោរឃៅណាស់ (បារាំង)។ ដូច្នោះ សរុបមក មួយជីវិតរបស់ខ្ញុំនោះ គ្មានសេចក្តីសុខទេ អសន្តិសុខក្នុងចិត្ត អសន្តិសុខក្នុងខួរក្បាលទាំងអស់ ហើយក៏កើតមានគំនិតខ្លាច[1] ។*

**ជនជាប់ចោទលោក នួន ជា**

## *ជំពូកទី១៖* ទិដ្ឋភាពទូទៅ

ដំណើរការនីតិវិធីសវនាការនៅសប្តាហ៍នេះ គឺបានបន្តស្តាប់ការផ្តល់សក្ខីកម្មបញ្ចប់របស់លោក **ឆាំង យុ** ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (តពីនេះហៅថា *ស៊ី.ឌី.ខេម*) និងសក្ខីកម្មរបស់លោក **នួន ជា** ។ អង្គជំនុំជម្រះបានបន្តពិភាក្សាលើបញ្ហានីតិវិធីស្តីពីឯកសារដែលស្នើដាក់បង្ហាញឡើងនៅចំពោះមុខអង្គជំនុំជម្រះ និងភាគីទាំងអស់ ដោយសារតែការខកខានមិនបានមកផ្តល់សក្ខីកម្មរបស់សាក្សីជំនាញ **អេលីហ្សាបេ៊ត បេកឃ័រ** *(Ms.Elizabeth Becker)* ។

នៅថ្ងៃច័ន្ទនេះ មេធាវីជាតិ និងអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** រួមមាន៖ លោក **ហ្សាស្ពើ ប៉ៅ** *(Mr. Jasper PAUW)* និងលោក **សុន អរុណ** បានបញ្ចប់ការសួរដេញដោលទៅលើសាក្សី **ឆាំង យុ** ។ នៅថ្ងៃអង្គារ មិនមានសវនាការទេ ដោយសារតែជាថ្ងៃឈប់សម្រាកបុណ្យសាសនាជាតិរបស់កម្ពុជា គឺពិធីបុណ្យមាឃបូជា ។ សវនាការបានបន្តធ្វើជាថ្មីនៅថ្ងៃពុធ ចាប់ផ្តើមដោយលោកមេធាវីអន្តរជាតិការពារក្តី **ម៉ៃខល ផេស្តមិន** *(Mr. Michiel PESTMAN)* បានសួរសំណួរទៅកាន់កូនក្តីរបស់គាត់គឺលោក **នួន ជា** ។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះ បានពិន័យមេធាវី **ផេស្តមិន** ដោយបានកាត់យកពេលវេលាក្នុងការសួរដេញដោលរបស់មេធាវីរូបនេះ បន្ទាប់ពីគាត់បានបានស្នើសុំម្តងហើយម្តងទៀតឲ្យតុលាការធ្វើការថ្កោលទោសលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន**

លើបញ្ហាដែលលោកនាយករដ្ឋមន្ត្រីបានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈស្តីអំពីពិរុទ្ធភាពរបស់កូនក្តីគាត់ ក្នុងពេលដែលសវនាការបាននឹងកំពុងតែបន្តដំណើរការនីតិវិធី។ ការផាកពិន័យរបស់អង្គជំនុំជម្រះបានធ្វើឡើងក្រោមហេតុផលថា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចបដិសេធរួចហើយ[2] ។ បន្ទាប់មកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** *(Jean-Marc Lavergne)* បានចាប់ផ្តើមសួរសំណួរទៅលោក **នួន ជា** ហើយបន្ថែមពីនេះ គាត់បានដាក់បង្ហាញឯកសារមួយចំនួនដើម្បីឲ្យលោក **នួន ជា** ផ្តល់ការអត្ថាធិប្បាយលើឯកសារទាំងនោះ ។

សវនាការនៅថ្ងៃព្រហស្បតិ៍ បានផ្តោតសំខាន់ទាក់ទងនឹងការដាក់បង្ហាញឯកសារ ដែលជាដំបូងត្រូវបានធ្វើឡើងដោយចៅក្រម **យ៉ា សុខន** ហើយបន្ទាប់មកទៀត ធ្វើឡើងដោយព្រះរាជអាជ្ញាអន្តរជាតិ លោក **ឌេល លីសាក់** *(Mr. Dale LYSAK)* ។ ក្រោយមក ដោយមានការស្នើសុំពីលោកមេធាវី **ផេស្តមិន** អង្គជំនុំជម្រះបានសម្រេចផ្តល់ពេលវេលាដើម្បីធ្វើការសួរដេញដោលលោក **នួន ជា** ទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅព្រឹកថ្ងៃព្រហស្បតិ៍ ។ ព្រះរាជអាជ្ញាជាតិ លោក **ច័ន្ទ តារាស្មី** បានបញ្ចប់ការអានអង្គហេតុស្របគ្នាមួយចំនួនរវាងភាគីព្រះរាជអាជ្ញា និងមេធាវីការពារក្តីលោក **អៀង សារី** ។

ពេញមួយសប្តាហ៍នេះ ជនជាប់ចោទ **អៀង សារី** និងជនជាប់ចោទ **ខៀវ សំផន** បានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ដោយឡែក លោក **នួន ជា** បានផ្តល់ការអត្ថាធិប្បាយលើឯកសារមួយចំនួន ហើយបានស្នើទាមទារសុំឯកសារដើម ឬយ៉ាងហោចណាស់ ជាឯកសារថតចម្លងចេញពីឯកសារដើមទាំងនោះ ដើម្បីឲ្យគាត់ធ្វើការបញ្ជាក់ និងសិក្សាបន្ថែមលើឯកសារដែលប្រើជាភស្តុតាងទាំងនោះ ។

## *ជំពូកទី២ ៖* សក្ខីកម្មសខេ្ខបរបស់សាក្សី

លោក **ឆាំង យុ** នាយក*ឌី.ស៊ី.ខេម* បានបន្តផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងវិធីសាស្ត្រប្រមែប្រមូលឯកសារ ការរៀបចំធ្វើកាតាឡុកឯកសារ និងការគ្រប់គ្រងឯកសារ ។ លោក **ឆាំង យុ** ក៏ត្រូវបានភាគីសួរផងដែរថាតើ *ឌី.ស៊ី.ខេម* ធ្វើការវាយតម្លៃ និងកំណត់ថាឯកសារទាំងនោះ ពិតជាបានធ្វើឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែនឬមិនមែនដោយរបៀបណា ។ នាសប្តាហ៍នេះ សក្ខីកម្មមួយទៀត ត្រូវបានធ្វើឡើងដោយជនជាប់ចោទ **នួន ជា** ដែលបានផ្តល់សក្ខីកម្មអំពីជីវប្រវត្តិផ្ទាល់ខ្លួន និងទំនាក់ទំនងរបស់គាត់ជាមួយនឹងលោក **ហេង សំរិន** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[3] ។

### ក. សក្ខីកម្មរបស់លោក ឆាំង យុ

នៅព្រឹកថ្ងៃច័ន្ទនាសប្តាហ៍នេះ មេធាវីការពារក្តីលោក **នួន ជា** បានធ្វើការចោទសួរលើសាក្សី **ឆាំង យុ** ។ ដោយសារមេធាវីការពារក្តីលោក **អៀង សារី** ប្រកាសថាក្រុមខ្លួនមិនមានសំណួរសួរលើសាក្សីទេ ទើបមេធាវីការពារក្តីលោក **នួន ជា** បានស្នើសុំម៉ោងបន្ថែមដើម្បីចោទសួរទៅកាន់សាក្សីដដែលនេះ ។ អង្គជំនុំជម្រះបានសម្រេចយល់ព្រមផ្តល់ពេលបន្ថែមមួយម៉ោងទៀតតាមការស្នើ ។

### *ក.១. ឯកសាររបស់ ឌី.ស៊ី.ខេម*

មេធាវីអន្តរជាតិការពារក្តី លោក **ហ្វាស្ទី ប៉ៅ** បានព្យាយាមរិះរកការបកស្រាយបញ្ជាក់ពី*ឌី.ស៊ី.ខេម*ចំពោះការដែលមជ្ឈមណ្ឌលនេះ បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសារមួយមានឈ្មោះថា "ទិន្នន័យដេតាបេស" ដែលនិយាយអំពីប្រល័យពូជសាសន៍នៅកម្ពុជា ហៅថា **ស៊ី.ប៊ី.អាយ.ប៊ី** *CBIB*[4] (*ឌី.ស៊ី.ខេម* ហៅថា **ស៊ីប៊ីប**) សម្រាប់ធ្វើការបញ្ចូលព័ត៌មានទៅក្នុងទិន្នន័យរបស់*ឌី.ស៊ី.ខេម* ។ យោងតាមសាក្សីបានឲ្យដឹងថា ឈ្មោះទិន្នន័យមួយនេះគឺមានផ្ទុកនូវរបៀបក្នុងការបញ្ចូលព័ត៌មានទាំងឡាយនៃឯកសារដើម និងព័ត៌មានមួយចំនួនពីអ្នករក្សាទុកនៅឯកសារពីមុនៗមក (ប្រវត្តិនៃការប្តូរពីម្ចាស់ដើមទី១ មកម្ចាស់ដើមទី២៖ អ្នកណាអ្នកកាន់កាប់ពីមុន អ្នកណាជាអ្នកកាន់កាប់បន្តទទួលដល់ដៃពីអ្នកណា...) ។ សាក្សី បានអះអាងថា *ឌី.ស៊ី.ខេម* បាននឹងកំពុងប្រើប្រាស់ទិន្នន័យមួយនេះ ហើយបានបន្តផ្តល់លេខកូដពិសេសដល់ឯកសារនីមួយៗ ដើម្បីសម្គាល់ពីចរិកលក្ខណៈនៃឯកសារដើមទាំងនោះ ។ លោក **ឆាំង យុ** ក៏បានទទួលស្គាល់ផងដែរថា *ឌី.ស៊ី.ខេម* មិនធ្លាប់បានធ្វើកោសល្យវិច័យលើឯកសារទេ ។ ក៏ប៉ុន្តែគាត់បានពន្យល់ថា *ឌី.ស៊ី.ខេម* ជាទូទៅសម្អាង "មើលពណ៌ មើលកាលបរិច្ឆេទ មើលលើសាច់រឿង មើលពីអ្នកនិពន្ធ មើលនូវទំហំរូបរាងរបស់វា[5]" ។

### *ក.២. បណ្ណសារដ្ឋានរបស់ព្រះអង្គម្ចាស់ នរោត្តមសីហនុ*

លោកមេធាវី **ប៉ៅ** បានចំណាយពេលវេលាមួយផ្នែករបស់គាត់ក្នុងការជជីកសួរដេញដោលអំពីទីកន្លែងជាក់លាក់ដែល *ឌី.ស៊ី.ខេម* បានប្រមែប្រមូលឯកសារ ដោយធ្វើការថតចម្លងចេញពីឯកសារដើម (*ឌី.ស៊ី.ខេម* បានថតចម្លងឯកសារស្តីពីកម្ពុជាប្រជាធិបតេយ្យចេញពីគេហទំព័ររបស់ព្រះអង្គម្ចាស់ **នរោត្តមសីហនុ** យកមករក្សាទុកនៅក្នុងទិន្នន័យរបស់មជ្ឈមណ្ឌលខ្លួន) ។ កាលពីខែមុន គឺនៅថ្ងៃទី២៥ ខែមករា ក្នុងអំឡុងពេលលោក **វ៉ានថាន់ ពៅដារ៉ា** មកផ្តល់សក្ខីកម្មហើយពេលនោះ សាក្សីរូបនេះ ត្រូវបានលោកមេធាវីការពារក្តី **កាណាវ៉ាស** សួរថាតើវាមានភាពងាយស្រួល ឬលំបាកដូចម្តេចខ្លះ "ក្នុងការចូលទៅកាន់គេហទំព័រ ឬបណ្ណសារដ្ឋានរបស់ព្រះមហាក្សត្រ **នរោត្តមសីហនុ** ដើម្បីដឹងថាឯកសារអ្វីខ្លះដែលព្រះអង្គមាន ហើយដែលឯកសារទាំងនោះមានទំនាក់ទំនងនឹងពេលវេលានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារណាខ្លះដែលអាចមានប្រយោជន៍ទាំងសម្រាប់ការិយាល័យព្រះរាជអាជ្ញា និងអង្គភាពការពារក្តី" ។[6] មេធាវី **ប៉ៅ** បានទាញយកប្រធានបទដដែលនេះ មកធ្វើការចោទសួរទៅកាន់សាក្សី **ឆាំង យុ** ដោយផ្តោតសំខាន់ទៅលើទីតាំងនៃការប្រមូលយកឯកសារទាំងនោះ ពីបណ្តុំឯកសាររបស់ព្រះមហាក្សត្រ **នរោត្តមសីហនុ** ។ សាក្សី **ឆាំង យុ** បានរម្លឹកថា *ឌី.ស៊ី.ខេម* បានព្រីនចេញឯកសារពាក់ព័ន្ធបានខ្លះៗដែលត្រូវបានដាក់បង្ហោះជាបណ្តោះអាសន្ននៅក្នុងគេហទំព័ររបស់ព្រះបាទ **នរោត្តមសីហនុ** ។ សាក្សីបានបញ្ជាក់ថាក្រុមការងារខ្លួនបានព្យាយាមព្រីនចេញ តែដោយសារតែអ៊ីនធឺណែតយឺតមិនអាចព្រីនចេញបានគ្រប់ឯកសារទាំងអស់នោះទេ ។ ក្រោយមក ព្រះករុណាបានសម្រេចព្រះទ័យថា ឯកសារទាំងអស់របស់ព្រះអង្គនេះ ត្រូវតែយកពីកម្ពុជាទៅរក្សាទុកនៅ*ប្រទេសប៊ែលហ្សិក* វិញ ។ ត្រង់ចំណុចនេះហើយ ឯកសារដែលថត

ចម្លងពីប្រព័ន្ធអេឡិចត្រូនិចទាំងអស់ក្រោយមកលែងមាននៅលើគេហទំព័រព្រះអង្គទៀតហើយ ។ លោក **ឆាំង យុ** បាននិយាយថា៖

> *ខ្ញុំចាំថានៅវិទ្យាស្ថានចុងបូព៌ា អ៊ីសស្ទឹម អូរីយ៉ង់តាល អ៊ិនស្ទីធូត ខ្ញុំគិតថានៅប្រទេសបែលហ្សិកដែរ ហើយមានការជជែកគ្នា ថាហេតុដូចម្តេចបានជាបណ្ណសារដ្ឋាននេះមិននៅស្រុកខ្មែរហើយបានប្រគល់ទៅឲ្យខាងណោះទៅវិញបាទ។ មានពេលមួយនោះ ខ្ញុំចង់កូពីចេញពីវេបសាយទាំងមូល ហើយខ្ញុំចាំថាមានពេលមួយនោះ ព្រះករុណាចង់លក់វេបសាយហ្នឹងទៅឲ្យអតិថិជន បើអ្នកណាត្រូវការវេបសាយនេះ។ ហើយខ្ញុំចាំថា អង្កាល់នោះ ប្រព័ន្ធអ៊ីនធឺណែតរបស់ស្រុកយើងវាស្លូ...(យឺត) វាយឺត អ៊ីចឹងយើងបានព្យាយាម ប៉ុន្តែហាក់ដូចជាមិនបានជោគជ័យទេ[8] ។*

តាមអ្វីដែលលោក **ឆាំង យុ** បានដឹងមានតែឯកសារថតចម្លងចេញពីឯកសារដើមទេដែលអាចរកបាននាពេលបច្ចុប្បន្ននេះ ។ ឯកសារមួយចំនួនដែលមាននៅ*បែលហ្សិក* ប្រហែលជាអាចស្នើសុំបានសម្រាប់ធ្វើកិច្ចការស្រាវជ្រាវ ។ សាក្សីមិនច្បាស់ថាតើខាងសាកលវិទ្យាល័យ គេបានរៀបចំឲ្យសាធារណជនអាចចូលរកមើលនូវឯកសារថតចម្លងអេឡិចត្រូនិចទាំងនោះតាមរយៈប្រព័ន្ធអ៊ីនធឺណែតបានឬយ៉ាងណានោះទេ ។ គាត់និយាយថា "ប្រហែលជាគេមានរបៀបរបបអាចឲ្យយើងទៅសិក្សាស្រាវជ្រាវបាន ខ្ញុំគិតថាលោកអាចសាកល្បងមើលបាន[9]។"

### *ក.៣. បណ្ណសារដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា*

សាក្សី **ឆាំង យុ** បានបញ្ជាក់ថា មុនឆ្នាំ១៩៩៣ គណបក្សប្រជាជនកម្ពុជា បានបង្កើតបណ្ណសារដ្ឋានមួយដែលមានការចូលរួមជាមួយ*ប្រទេសវៀតណាម* និង*ប្រទេសឡាវ* ។ ក៏ប៉ុន្តែ សាក្សីមិនដឹងទេថាហេតុអ្វីបានជាបណ្ណសារដ្ឋាននោះបានបិទនៅឆ្នាំ១៩៩៣ ។ សាក្សីបានបរិយាយទៀតថា គាត់ព្យាយាមស្វែងរកឯកសារកម្ពុជាដែលពាក់ព័ន្ធទៅនឹងបណ្ណសារដ្ឋាន ដោយគាត់បានធ្វើដំណើរទៅ*ប្រទេសឡាវ* និង*វៀតណាម* ក៏ប៉ុន្តែគាត់រកមិនបាន ។ លោកមេធាវី **ប៉ៅ** បានសួរទៅកាន់សាក្សីយ៉ាងដូច្នេះថា៖ "តើលោកដឹងថា បច្ចុប្បន្ននេះ គណបក្សប្រជាជនកម្ពុជានៅតែមានឯកសារដែលគេបានរក្សាទុកកាលចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គឺសម័យកម្ពុជាប្រជាធិបតេយ្យដែរ ឬទេ ?[10]" លោក **ឆាំង យុ** បានឆ្លើយតបថា៖

> *ខ្ញុំថា បើសិនជាមានក៏មាននៅក្នុងលក្ខណៈបុគ្គល ពីព្រោះស្ថាប័នវាបិទទៅហើយ.... ខ្ញុំគិតថា ជាបុគ្គល សមាជិករាជរដ្ឋាភិបាល ឬគណបក្សប្រជាជនកម្ពុជាទើបអាចមានឯកសារជាបុគ្គល បាទជាបុគ្គល។ ប៉ុន្តែបើនិយាយអំពីគណបក្សទាំងមូល ស្ថាប័នដែលគ្រប់គ្រងឯកសារទាំងអស់នោះគឺបានបិទហើយតាំងពីឆ្នាំ១៩៩៣ គឺជាបណ្ណសារដ្ឋានជាតិប្រវត្តិបក្សគណបក្សប្រជាជនបដិវត្តន៍កម្ពុជាបិទទៅហើយ។ តែជាបុគ្គលខ្ញុំគិតថានៅមាន។ ពីព្រោះមានបុគ្គលក៏បានផ្តល់ឲ្យខ្ញុំដែរ[11] ។*

## ខ. ការផ្តល់សក្ខីកម្មរបស់លោក នួន ជា

ទោះបីជា អង្គជំនុំជម្រះបានហាមប្រាមលោក **ផេស្តមិន** មិនឲ្យបន្តសួរសំណួរទៅកាន់លោក **នួន ជា** កាលពីថ្ងៃពុធក៏ដោយ ក៏អង្គជំនុំជម្រះបានសម្រេចផ្តល់បន្ថែមពេលវេលាសម្រាប់មេធាវីរូបនេះ ឲ្យសួរសំណួរដល់

កូនក្ដីខ្លួននៅថ្ងៃព្រហស្បតិ៍វិញ ។ លោក **ផេស្តមិន** បានផ្ដោតសំខាន់នូវការសួរសំណួររបស់ខ្លួនលើពីរចំណុចដែលត្រូវបានជជែកម្ដងហើយ កាលពីថ្ងៃអង្គារ ទី៣១ ខែមករា ។ ចំណុចទាំងពីរគឺ៖ ជីវប្រវត្តិលោក **នួន ជា** និងមុខងារលោក **ហេង សំរិន** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

### *ខ.១. ជីវប្រវត្តិលោក នួន ជា*

លោក **ផេស្តមិន** បានសួរសំណួរមួយចំនួនស្ដីអំពីស្ថានភាពសេដ្ឋកិច្ចក្នុងក្រុមគ្រួសាររបស់លោក **នួន ជា** និងការកត់សម្គាល់របស់លោក **នួន ជា** ចំពោះការធ្វើបាបប្រជាជនខ្មែរក្នុងរបបអាណានិគមបារាំង ។ លោក **នួន ជា** បានផ្ដល់សក្ខីកម្មថា ឪពុករបស់គាត់ជាអ្នករកស៊ីទិញដូរស្រូវ ហើយក្រោយសង្គ្រាមលោកលើកទីមួយស្រូវសម័យនោះ វាចុះថ្លៃច្រើនពេក ជាហេតុធ្វើឲ្យឪពុកគាត់ជំពាក់លុយគេ ។ ជនជាប់ចោទបានប្រាប់ថា ឪពុកគាត់បានប្រឹងប្រែងរកលុយសងគេបួនដប់ម្ភៃឆ្នាំ ដោយសងតែការប្រាក់គេក៏សងមិនរួចផង។ លោក **នួន ជា** បានប្រាប់តុលាការថា គាត់បានឃើញពីការធ្វើបាបអ្នកបម្រើ ហើយនិងអ្នកភូមិ ការចាប់រំលោភយ៉ាង "ឃោរឃៅ"[12]ក្នុងពេលដែលកម្ពុជានៅស្ថិតក្រោមអាណាព្យាបាលបារាំង ។ គាត់បានថ្លែងថា ការធ្វើទុក្ខបុកម្នេញរបស់បារាំងកាលហ្នឹងនាំឲ្យកើតមានការស្អប់អំពើអយុត្តិធម៌ ក៏មានចិត្តអាណិតអាសូរជាតិឯង និងប្រជាជនឯង[13]។

កាលដែលលោក **នួន ជា** នៅជាយុវជននៅឡើយ គាត់បានទៅរៀននៅ*ប្រទេសថៃ* ។ គាត់បានថ្លែងពីការសោកស្ដាយថា "ខ្ញុំស្មានតែថៃមានឯករាជ្យ ប៉ុន្តែការពិតមិនមែនឯករាជ្យទេ គេធ្វើរដ្ឋប្រហារបាញ់នាយក--បាញ់រដ្ឋមន្ត្រីស្លាប់បីបួននាក់ ។ ខ្ញុំឃើញថារកយុត្តិធម៌មិនឃើញទេ"[14] លោក **នួន ជា** និយាយបន្ថែមថា គាត់បានបោះបង់ការសិក្សា ពីព្រោះគាត់គិតថានៅរៀនទៀតក៏ឥតប្រយោជន៍ ។ គាត់ក៏បានចូលរួមជាមួយនឹងពួកឥស្សរៈឬចលនាតស៊ូប្រឆាំងបារាំងនៅឆ្នាំ១៩៥០ ។ ក្នុងឆ្នាំ១៩៥៣ គាត់បានបន្តការសិក្សានៅភាគខាងជើង*ប្រទេសវៀតណាម* អស់រយៈពេលបី ឬបួនឆ្នាំ និងបានត្រឡប់មកកាន់មាតុប្រទេសវិញ បន្ទាប់ពីកម្ពុជាបានធ្វើកិច្ចព្រមព្រៀងនៅ*ទីក្រុងហ្សឺណែវ*នៅឆ្នាំ១៩៥៤ ។

### *ខ.២. មុខងារលោក ហេង សំរិន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

លោក **នួន ជា** បានពន្យល់ប្រាប់តុលាការថា បន្ទាប់ពី*កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ* មុនឆ្នាំ១៩៧៥ លោក **ហេង សំរិន** ជាអ្នកនាំផ្លូវ និងបាននាំផ្លូវលោក **នួន ជា** ទៅកាន់ព្រំដែន*វៀតណាម*នៅរៀងរាល់ពីរខែម្ដង ។ លោក **នួន ជា** បានធ្វើដំណើរទៅព្រំដែនដើម្បីចរចា និងរកដំណោះស្រាយជាមួយនឹង*វៀតណាម*នៅពេលកងទ័ពមានការប៉ះទង្គិចគ្នាញឹកញាប់រវាង*កម្ពុជា* និង*វៀតណាម* ។ បន្ទាប់ពីការរំដោះនៅឆ្នាំ១៩៧៥ ការធ្វើដំណើរទៅកាន់*ប្រទេសវៀតណាម* គឺមិនចាំបាច់ដើរកាត់ព្រៃដូចមុនទេ ព្រោះមានផ្លូវផ្សេងអាចឆ្លងកាត់បាន ។ យោងតាមលោក **នួន ជា** បានឲ្យដឹងថា លោក **ហេង សំរិន** នៅពេលនោះបានក្លាយទៅជាមេបញ្ជាការទៅហើយ ។ មេធាវី **ផេស្តមិន** បានសួរកូនក្ដីរបស់គាត់ថា តើត្រឹមត្រូវដែរឬទេដែលលោក **ហេង សំរិន** គឺជាមេដឹកនាំកងពលមួយរូបកាលពីសម័យនោះ ដែលបានចូលរួមវាយរំដោះយក*ទីក្រុងភ្នំពេញ* និងកំពុងតែនៅរស់រានមានជីវិតនៅឡើយ ។

ទោះជាយ៉ាងនេះក្តី លោកប្រធានតុលាការ **និល ណុន** បានប្រាប់លោក **នួន ជា** កុំឲ្យឆ្លើយតបទៅនឹងសំណួរនេះ ដោយហេតុថាមិនមានការជាប់ពាក់ព័ន្ធ ។

## *ជំពូកទី៣ ៖* បញ្ហានីតិវិធី និងច្បាប់

ក្នុងអំឡុងពេលដំណើរការនីតិវិធីសវនាការនៅសប្តាហ៍នេះ អង្គជំនុំជម្រះ និងភាគី បានដាក់បង្ហាញឡើងនូវឯកសារ និងផ្តល់មតិយោបល់លើភស្តុតាងជាឯកសារទាំងនោះ ។ តាមរយៈការបង្ហាញទាក់ទងនឹងឯកសារនានា ភាគីបានស្វះស្វែងសុំឲ្យមានការណែនាំពីអង្គជំនុំជម្រះលើបញ្ហាដែលទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទ ជាពិសេសនោះ គឺសិទ្ធិនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី ។ ដូចសប្តាហ៍មុនដែរ ភាគីបានជំទាស់ម្តងហើយម្តងទៀតពីសំណួរមួយទៅសំណួរមួយទៀត ដោយសារតែពួកគេគិតថា សំណួរទាំងនោះមិនជាប់ពាក់ព័ន្ធ ឬជាសំណួរបែបប្រមាណវិធី (ស្មាន) ។

### ក. ការដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះ

នៅសប្តាហ៍នេះ អង្គជំនុំជម្រះ និងភាគីទាំងអស់ មានឱកាសក្នុងការដាក់បង្ហាញ និងផ្តល់មតិយោបល់លើភស្តុតាងជាឯកសារ ។ នៅថ្ងៃពុធ ប្រធានតុលាការ លោកចៅក្រម **និល ណុន** បានជូនវេទិកានេះដល់ចៅក្រម **ឡាវែន៍** ដើម្បីធ្វើការបង្ហាញឯកសារមុនភាគីដទៃៗទៀត។ ការអនុញ្ញាតនេះ ធ្វើឡើងដោយផ្អែកលើវិធាន ៨៣ (៣) នៃវិធានផ្ទៃក្នុង **អ.វ.ត.ក** ដែលចែងថា៖

> *អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង បើភាគីយកភស្តុតាងទាំងនោះមកដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯង យកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគីបើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេបត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ ។*

យោងតាមវិធានផ្ទៃក្នុង វាមិនមែនមានន័យថា មានតែភាគីទេ ដែលត្រូវដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែអង្គជំនុំជម្រះខ្លួនឯងផ្ទាល់ក៏អាចលើកឡើងបង្ហាញឯកសារនានានៅចំពោះមុខតុលាការ ហើយអនុញ្ញាតឲ្យភាគីធ្វើការឆ្លើយតបបានផងដែរ ។

ចៅក្រម **ឡាវែន៍** បានដាក់បង្ហាញឯកសារ ហើយបានដកស្រង់ខ្លឹមសារមួយចំនួនចេញពីឯកសារនោះ ដើម្បីសួរជនជាប់ចោទឲ្យផ្តល់ការអត្ថាធិប្បាយលើប្រធានបទនានាដែលរួមមាន៖

(i) សុន្ទរកថារបស់លោក **ប៉ុល ពត** អំពីបញ្ហាទម្រង់ផ្សេងៗគ្នានៃការតស៊ូបដិវត្តន៍
(ii) ការជម្លៀសប្រជាជន (ពីទីប្រជុំជនទៅទីជនបទ)

(iii) ការវាយយកក្រុងឧដុង្គ
(iv) សេចក្តីថ្លែងការណ៍ស្តីអំពីជ័យជម្នះធ្វើដោយលោក **ខៀវ សំផន** បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ។
(v) សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទៅកាន់អង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៧៣ ដោយបានបង្ហាញក្នុងកម្មវិធីនយោបាយ បូករួមទាំងការធានានូវសេរីភាពលើជំនឿ សាសនា ការគោរពកម្មសិទ្ធិ សេរីភាព និងសិទ្ធិលើកម្មសិទ្ធិឯកជន។
(vi) តារាងរាយនាមមន្ត្រីរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និង
(vii) មាត៌ាផ្ទៃក្នុង និងផ្នែកខាងក្រៅប្រាំបីចំណុចរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

លោក **នួន ជា** បានបកស្រាយថា លោកមិនបានជាប់ពាក់ព័ន្ធដឹងឮអំពីរដ្ឋបាលបក្ស ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ការងាររបស់លោកនៅពេលនោះ គឺអប់រំតែមួយមុខគត់ ។ គាត់បានពន្យល់ពីមុខងាររបស់គាត់ដូចតទៅនេះ៖

> *សូមគោរពលោកប្រធាន ការអប់រំរបស់បក្ស សំដៅកម្ចាត់ធាតុបុគ្គលនិយម អាជ្ញានិយមពុករលួយ កសាងគោលជំហរស្នេហាជាតិ ស្នេហាប្រជាជនស្នេហាបក្ស។ តស៊ូដាច់ខាត លះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីផលប្រយោជន៍រួម កាលណាមានទំនាស់រវាងផលប្រយោជន៍ផ្ទាល់ខ្លួននឹងប្រយោជន៍រួម ត្រូវគិតផលប្រយោជន៍រួមមុន។ នេះ គោលការណ៍ធំមួយរបស់បក្ស។ ខ្ញុំអប់រំតែខាងកម្ចាត់ធាតុបុគ្គលនិយម អានោះវាធំណាស់ អំណាចនិយម លុយកាក់និយម*[15] ។

នៅថ្ងៃព្រហស្បតិ៍ ចៅក្រម **យ៉ា សុខន** បានបង្ហាញឯកសារដែលទាក់ទងនឹងប្រវត្តិកម្ពុជាប្រជាធិបតេយ្យ ហើយបានអានសង្ខេបនូវឯកសារចំនួន១៧[16] នៅចំពោះមុខភាគីដទៃនៃអង្គជំនុំជម្រះ ។ លោកចៅក្រម ក៏បានស្នើជនជាប់ចោទឲ្យធ្វើការអត្ថាធិប្បាយ (ផ្តល់យោបល់) លើឯកសារទាំងនោះ ក៏ប៉ុន្តែមិនមានការអត្ថាធិប្បាយណាមួយត្រូវបានផ្តល់ជូនឡើយ ។

បន្ទាប់ពីចៅក្រម **យ៉ា សុខន** បានបញ្ចប់ទៅ ព្រះរាជាអាជ្ញា **លីសាក់** បានដាក់បង្ហាញឯកសារគាំទ្រលើការចោទប្រកាន់របស់ខ្លួន ដោយបានចោទថាលោក **នួន ជា** ការពិតទៅជាអ្នកទទួលខុសត្រូវផ្នែកយោធាហើយលោក **នួន ជា** ផ្ទាល់ក៏ធ្លាប់មានឋានៈជាប្រធានរដ្ឋ នៅពេលដែលលោក **ប៉ុល ពត** ឈឺអស់រយៈពេល៦ខែ ។ រីឯព្រះរាជអាជ្ញា **ច័ន្ទ តារាស្មី** វិញបានថ្លែងថា លោក **នួន ជា** និងលោក **ខៀវ សំផន** មិនព្រមទទួលស្គាល់នូវអង្គហេតុចោទប្រកាន់ទាំងឡាយណា ដែលមាននៅក្នុងដីកាដំណោះស្រាយទេ ។ ដោយឡែក ក្រុមមេធាវីការពារក្តីលោក **អៀង សារី** បានផ្តល់អង្គហេតុស្របគ្នាទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងសកម្មភាពដទៃទៀតរបស់លោក **អៀង សារី** នៅមុនឆ្នាំ១៩៦៥ ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ ។ បន្ទាប់មកលោក **ច័ន្ទ តារាស្មី** បានអានអង្គហេតុស្របគ្នារវាងភាគីព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីឲ្យលោក **អៀង សារី**[17]។

## ខ. សិទ្ធិជនជាប់ចោទ

មានបញ្ហាខ្លះៗ បានកើតឡើងទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងអំឡុងពេលដំណើរការសវនាការនីតិវិធី ឬករួមទាំងជម្លោះមួយចំនួនស្តីពីការបំពារបំពានសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ ហើយនិងថាតើពេលវេលាប៉ុណ្ណាដែលត្រូវបានចាត់ទុកថាជាពេលវេលាគ្រប់គ្រាន់សម្រាប់ការរៀបចំការពារក្តី។ បន្ថែមពីនេះ តុលាការក៏បានពិភាក្សាផងដែរអំពីការចេញសេចក្តីសម្រេចលើការជំទាស់នានា ក្រោមហេតុផលថា សំណួរមិនមានការជាប់ពាក់ព័ន្ធ ឬសួរឲ្យសាក្សីឆ្លើយស្មានៗ ។ រីឯបញ្ហាមួយទៀតនោះ គឺភាគីបានសាកសួរទៅកាន់អង្គជំនុំជម្រះជាសាថ្មី ទាមទារឲ្យមានការដោះស្រាយចំពោះសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅក្នុងសន្និសិទកាសែតនៅ*ប្រទេសវៀតណាម*។

### *ខ.១. សិទ្ធិនៅស្ងៀមមិនឆ្លើយតប*

នៅថ្ងៃពុធ ចៅក្រម **ឡាវែន៍** បានធ្វើការចោទសួរទៅកាន់លោក **ខៀវ សំផន** ជាថ្មីម្តងទៀត ដោយស្នើឲ្យជនជាប់ចោទផ្តល់ការអត្ថាធិប្បាយលើឯកសារនានាដែលលោកចៅក្រមបានដាក់បង្ហាញនៅចំពោះមុខ ។ ក៏ប៉ុន្តែលោក **ខៀវ សំផន** បានបដិសេធមិនធ្វើការអត្ថាធិប្បាយលើឯកសារទាំងនោះទេដោយបានបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់ ។ ហើយបញ្ហានេះ បានកើតឡើងសាជាថ្មីម្តងទៀតនៅថ្ងៃព្រហស្បតិ៍ នៅពេលដែលចៅក្រម **យ៉ា សុខន** បានអានជាសង្ខេបនូវឯកសារនានានៅចំពោះមុខភាគី ហើយស្នើសុំឲ្យជនជាប់ចោទធ្វើការអត្ថាធិប្បាយ ។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **អៀង សារី** គឺលោក **ម៉ៃខល កាណាវ៉ាស** *(Mr. Michael KARNAVAS)* បានសួរថាតើបទដ្ឋានអន្តរជាតិគួរតែយកមកអនុវត្តក្នុង **អ.វ.ត.ក** ដែលផ្តល់នូវឋានៈរបស់អង្គជំនុំជម្រះជាតុលាការអន្តរជាតិមួយ ។ លោក **កាណាវ៉ាស** បានថ្លែងដូចខាងក្រោមនេះ៖

> *ក្នុងរយៈពេលបួនឆ្នាំកន្លងមកហើយខ្ញុំបានឮថា តុលាការនេះ គឺជាតុលាការអន្តរជាតិដែលគួរតែនឹងអនុវត្តនូវស្តង់ដារអន្តរជាតិ ។ ខ្ញុំមិនដឹងថា មានតុលាការអន្តរជាតិណាមួយ ឬក៏តុលាការកូនកាត់ណាមួយ ឬក៏តុលាការជាតិណាមួយ ដែលទទួលបានមូលនិធិពីអង្គការសហប្រជាជាតិ បែរជាបន្តទទូច និងតាំងសំណួរទៅលើជនជាប់ចោទ ទោះបីជាជនជាប់ជោទនោះបានចង្អុលបង្ហាញយ៉ាងច្បាស់ថាខ្លួនសុំរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ។ ដូច្នេះ ខ្ញុំគិតថានេះ ជាការរំលោភបំពានលើដំណើរការនីតិវិធី[18] ។*

យោងតាមលោក **កាណាវ៉ាស** ការបន្តស្នើសុំជនជាប់ចោទឲ្យឆ្លើយជាការបំពានសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ ហើយនេះអាចចាត់ទុកថាជាទម្រង់នៃការបង្ខិតបង្ខំ ។ លោក **កាណាវ៉ាស** បញ្ជាក់ថាការអនុវត្តន៍នូវនីតិវិធីបែបនេះ វានាំមកនូវការខាតពេលវេលា និងខ្ជះខ្ជាយធនធានរបស់តុលាការ ។ ជាលទ្ធផលលោកបានស្នើសុំឲ្យអង្គជំនុំជម្រះបញ្ចប់ការអនុវត្តន៍នីតិវិធីបែបនេះ ។ លោកប្រធានអង្គជំនុំជម្រះ ឆ្លើយតបថាការស្នើសុំឲ្យជនជាប់ចោទធ្វើការអត្ថាធិប្បាយឯកសារដែលពាក់ព័ន្ធមិនមែនជាទម្រង់នៃការបង្ខិតបង្ខំនោះទេ ប៉ុន្តែ

ឯកសារភស្តុតាងនោះពាក់ព័ន្ធផ្ទាល់ទៅនឹងជនជាប់ចោទ ។ បន្ទាប់មកទៀតលោកប្រធាន បានណែនាំឲ្យចៅក្រម **យ៉ា សុខន** បន្តអានឯកសារទាំងឡាយឲ្យលឿនៗដោយមិនចាំបាច់ស្នើឲ្យជនជាប់ចោទធ្វើអត្ថាធិប្បាយលើឯកសារទាំងនោះទេ ប៉ុន្តែចៅក្រមបានប្រាប់ថា បើលោក **ខៀវ សំផន** ចង់ធ្វើអត្ថាធិប្បាយ គាត់អាចធ្វើបាន ។

### *ខ.២. សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន*

លោក **នួន ជា** ជាជនជាប់ចោទមួយនាក់គត់ដែលបានធ្វើអត្ថាធិប្បាយលើឯកសារភស្តុតាងដែលព្រះរាជអាជ្ញាបានបង្ហាញក្នុងសប្តាហ៍នេះ ខណៈដែលលោក **ខៀវ សំផន** និងលោក **អៀង សារី** បានបន្តអនុវត្តនសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។ មានពេលមួយនោះ លោក **នួន ជា** បានទាមទារឲ្យមានឯកសារដើមជាភាសាខ្មែរដោយគាត់បានថ្លែងដូចខាងក្រោមនេះថា៖

> *ខ្ញុំមិនយល់ទាល់តែសោះ ម៉េចក៏ពិបាកម្ល៉េះ គ្រាន់តែស្នើសុំឯកសារដើមមកឲ្យខ្ញុំមើល! ស្តាប់យល់ទេ ទាល់តែយកមកពិនិត្យពិចារណាឲ្យច្បាស់លាស់សិន ។ លោកគ្រាន់តែអានៗ ហើយមកឲ្យខ្ញុំឆ្លើយយ៉ាងម៉េច[19] ?*

លោក **លីសាក់** បានស្រុះស្រួលទៅការស្នើសុំរបស់លោក **នួន ជា** ហើយបានផ្តល់ឯកសារថតចម្លងមួយចំនួនដល់គាត់ ។ លោកប្រធានអង្គជំនុំជម្រះ បានអរគុណព្រះរាជអាជ្ញា ហើយនិយាយថា វាជាតួនាទីរបស់មេធាវីការពារក្តីទេដែលជាអ្នកផ្តល់ឯកសារ ពីព្រោះឯកសារទាំងអស់គឺមាននៅក្នុងសំណុំរឿង ។

## គ. ការជំទាស់ទៅនឹងសំណួរដែលមិនពាក់ព័ន្ធ ឬសំណួរដែលនាំឲ្យមានការឆ្លើយស្មានៗ

អស់រយៈពេលពេញមួយសប្តាហ៍ ភាគីបានលើកឡើងនូវការជំទាស់ទៅនឹងសំណួរមួយចំនួន ក្រោមហេតុផលថា ជាសំណួរច្រំដែល ជាសំណួរដែលគ្មានភាពពាក់ព័ន្ធ ឬសំណួរបែបប្រមាណវិធី ។ ជាឧទាហរណ៍ កាលពីថ្ងៃច័ន្ទ ព្រះរាជអាជ្ញា **អាប់ឌុលឡាក់** *(Mr. ABDULHAK)* បានជំទាស់ទៅនឹងសំណួររបស់មេធាវី **ប៉ៅ** ដោយឈរលើហេតុផលថា ជាសំណួរនាំឲ្យសាក្សីឆ្លើយស្មាន ។ លោក **ប៉ៅ** បានសួរទៅកាន់សាក្សី **ឆាំង យុ** ថាតើលោក **ឆាំង យុ** ជឿទេថា*វៀតណាម* ពិតជាបានបំផ្លាញវត្ថុតាងជាក់បន្ទុកនានា ក្រោយពីឆ្នាំ១៩៧៩ ។ ព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានលើកឡើងនូវការជំទាស់ដូចគ្នាពេលដែលមេធាវី **ប៉ៅ** បានសួរថា តើឯកសារអ្វីខ្លះដែល*វៀតណាម*បានប្រើប្រាស់សម្រាប់កាត់ទោសលោក **ប៉ុល ពត** និងលោក **អៀង សារី** កាលពីឆ្នាំ១៩៧៩ ។ ក្រោយមកទៀត លោក **អាប់ឌុលឡាក់** បានធ្វើការជំទាស់ម្តងទៀតដោយលើកឡើងថា ជាសំណួរដែលមិនជាប់ពាក់ព័ន្ធ ។ លោក **ប៉ៅ** បានព្យាយាមបង្វែរប្រធានបទថ្មី និងបានពិភាក្សាលើបញ្ជីកាតាឡុកផ្សេងៗរបស់ *ឌី.ស៊ី.ខេម* ដោយបានបែងចែកឈ្មោះ និងប្រភេទឯកសារដែលខ្លួនមានជាផ្នែកៗ ។ បន្ថែមពីនេះ លោកប្រធានអង្គជំនុំជម្រះបានរម្លឹកមេធាវី **ប៉ៅ** ឲ្យកម្រិតសំណួរទាំងឡាយរបស់ខ្លួន ត្រឹមតែអង្គហេតុ ដែលទាក់ទងនឹងឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ប្រធានតុលាការបានពន្យល់ដូចតទៅនេះ៖

*គឺអង្គជំនុំជម្រះ ផ្តល់វេទិកាឲ្យលោកសួរសំណួរជាក់លាក់ពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការទទួលឯកសារ ការរៀបចំឯកសារជាកាតាឡុក ការគ្រប់គ្រងឯកសារ ឬ/និងប្រភេទឯកសារជាក់លាក់មួយចំនួនទៀត ។ យើងនឹងមិនអនុញ្ញាតឲ្យលោកដាក់ឯកសារនេះសួរដេញដោលទៀតទេ ។ សូមលោកតម្រង់ទិសទៅតាមគម្រោងផែនការដែលអង្គជំនុំជម្រះបានកំណត់ទុកអំពីកម្មវត្ថុ ឬក៏បញ្ហាដែលភាគីត្រូវមានសិទ្ធិក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ ។ យើងសូមរំឭកថា ការកំណត់កាលបរិច្ឆេទនៃការសួរដេញដោលចំពោះសាក្សី គឺមិនមានការសួរដេញដោលលើឯកសារជាក់លាក់នីមួយៗឡើយ។ រីឯការជំទាស់ដេញដោលលើឯកសារជាក់លាក់នីមួយៗ នឹងត្រូវធ្វើឡើងនៅពេលក្រោយ*[20] ។

ក្នុងអំឡុងពេលសួរដេញដោលលើសាក្សី **ឆាំង យុ** លោកមេធាវី **ប៉ៅ** បានព្យាយាមបង្ហាញថាអ្វីដែលក្រុមមេធាវីការពារក្តីលោក **នួន ជា** ជឿនោះ គឺថាទី១ការចោទប្រកាន់របស់លោក **ឆាំង យុ** ថាជាមេដឹកនាំខ្មែរក្រហមគឺមានពិរុទ្ធភាព ដែលការចោទប្រកាន់បែបនេះ បានបង្ហាញពីភាពលម្អៀងចេញពីការងាររបស់គាត់ ។ ទី២ គឺមានការជ្រៀតជ្រែកពីរាជរដ្ឋាភិបាលកម្ពុជានៅក្នុងស្ថាប័នមួយនេះ ។ ព្រះរាជអាជ្ញា បានជំទាស់ដោយទទូចទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី ដោយបានលើកហេតុផលថា ជាសំណួរដែលគ្មានការជាប់ពាក់ព័ន្ធ ។ អង្គជំនុំជម្រះ បានសម្រេចយល់ស្របរាល់ការជំទាស់ទាំងអស់របស់ភាគីព្រះរាជអាជ្ញា លើកលែងតែករណីមួយ[21] ហើយបានលើកឡើងថា ប្រធានបទនៃសវនាការបច្ចុប្បន្ននេះ គឺផ្តោតទៅលើវិធីសាស្ត្ររបស់ *ឌី.ស៊ី.ខេម* ក្នុងការប្រមូលឯកសារ និងការធ្វើកាតាឡុកឯកសារ ។

មានចំណុចសំខាន់មួយ គឺថាលោក **ប៉ៅ** បានសួរសំណួរមួយស្តីពី "ទម្រង់នៃការបញ្ចូលព័ត៌មាន" ដែល *ឌី.ស៊ី.ខេម*ប្រើប្រាស់ក្នុងការបញ្ចូលឯកសារនានាដែលខ្លួនមាន ។ មេធាវី **ប៉ៅ** បានស្នើសុំឲ្យសាក្សី **ឆាំង យុ** ជួយបកស្រាយលម្អិតលើចំណារ ឬកំណត់សម្គាល់ដែលមាននៅលើទម្រង់បញ្ចូលព័ត៌មានរបស់ *ឌី.ស៊ី.ខេម* ដែលបានចង្អុលបង្ហាញអំពីប្រភពដើមនៃឯកសារ និងធ្វើការចារលើឯកសារនីមួយៗនោះថា ជាប្រភេទឯកសារដើម ឬឯកសារថតចម្លង ។ នៅចុងបញ្ចប់នៃការសួរដេញដោលរបស់មេធាវី **ប៉ៅ** លើសាក្សីរូបនេះ គាត់បានស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ទៅលោក **ឆាំង យុ** ឲ្យផ្តល់៖ ទី១ ព័ត៌មានបញ្ជាក់ថាតើឯកសារនៅ *ឌី.ស៊ី.ខេម* ជាឯកសារដើម ឬមិនមែន ។ ទី២ សូមឲ្យផ្តល់ពត៌មានទាក់ទងនឹងប្រភពដើមនៃឯកសារ ហើយនិងជួយចង្អុលបង្ហាញនូវអ្នកដែលបានកាន់កាប់ឯកសារទាំងនោះនាពេលមុនៗ ។ លោក **ប៉ៅ** បានស្នើសុំបន្ថែមទៀតថា ការស្នើសុំព័ត៌មានបញ្ជាក់ទាំងនេះ គួរតែត្រូវបានធ្វើឡើងរាល់គ្រប់ឯកសារទាំងអស់របស់ *ឌី.ស៊ី.ខេម* ដែលមាននៅក្នុងបញ្ជីឯកសារដែលភាគីព្រះរាជអាជ្ញាយកមកប្រើប្រាស់ជាឯកសារភស្តុតាងរបស់ខ្លួនក្នុងតុលាការនេះ។ លោកមេធាវី ក៏បានស្នើផងដែរថា សុំឲ្យសាក្សីរូបនេះ ចូលមកបង្ហាញខ្លួននៅក្នុងសវនាការក្រោយៗជាថ្មីម្តងទៀត ដើម្បីឆ្លើយបំភ្លឺទៅនឹងចម្ងល់ផ្សេងៗ ដែលអង្គជំនុំជម្រះចាត់ទុកថា វានៅក្រៅពីវិសាលភាពនៃដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ ។

លោកចៅក្រម **ឡាវែន៍** បានថ្លែងដូច្នេះថា ឯកសារទាំងនេះ បានដាក់ក្នុងសំណុំរឿងអស់រយៈពេលបីឆ្នាំមកហើយ ហើយលោក **ប៉ៅ** គួរតែបានសួរនាំពីបញ្ហានេះតាំងពីមុនមកម្ល៉េះ ។ ទោះជាយ៉ាងនេះក្តីយោងតាមលោក **ប៉ៅ** បានឲ្យដឹងថា គាត់មិនអាចដឹងបានទេថា តើឯកសារនៅក្នុងបញ្ជីណាខ្លះដែលនឹងយកមកប្រើប្រាស់ហើយក្រុមរបស់ខ្លួន ទើបតែរកឃើញនូវព័ត៌មានដែលមានក្នុងកំណត់សម្គាល់នានានៃទម្រង់បញ្ចូលព័ត៌មានរបស់ *ឌី.ស៊ី.ខេម* នាពេលថ្មីៗនេះតែប៉ុណ្ណោះ ។ អង្គជំនុំជម្រះ មិនបានធ្វើការសម្រេចលើបញ្ហានេះភ្លាមៗទេ ផ្ទុយទៅវិញ បានណែនាំឲ្យមេធាវីការពារក្តីលោក **នួន ជា** ដាក់សំណើជាលាយលក្ខណ៍អក្សរ ទើបអង្គជំនុំជម្រះអាចឆ្លើយតបស្របតាមខ្លឹមសារដែលនឹងស្នើសុំនោះ ។

## ឃ. ការសម្រេចលើការថ្លែងសុន្ទរកថារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងការប្រើប្រាស់ពេលវេលាក្នុងការចោទសួរលើលោក នួន ជា

យោងតាមការកំណត់ក្នុងកាលវិភាគលោកមេធាវី **ផេស្តមិន** នឹងត្រូវតាំងសំណួរសួរទៅកាន់កូនក្តីរបស់គាត់ គឺលោក **នួន ជា** នៅព្រឹកថ្ងៃពុធ ។ ទោះជាយ៉ាងនេះក្តី មុននឹងគាត់ចាប់ផ្តើម គាត់បានស្នើសុំឲ្យអង្គជំនុំជម្រះឲ្យផ្តល់ការកត់សម្គាល់ទាក់ទងនឹងបញ្ហានៃការថ្លែងសុន្ទរកថារបស់នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលបានធ្វើឡើងនៅ*ប្រទេសវៀតណាម* ។ យោងតាមប្រធានតុលាការ បានថ្លែងឲ្យដឹងថា អង្គជំនុំជម្រះបានដោះស្រាយបញ្ហានេះរួចរាល់ហើយ។ ក្រោយពីនេះ លោកប្រធានក៏បានណែនាំឲ្យលោក **ផេស្តមិន** ចាប់ផ្តើមតាំងសំណួរទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងរបៀបវារៈសម្រាប់សវនាការនៅសប្តាហ៍នេះ ។ ចៅក្រម **និល ណុល** បានថ្លែងថា៖

> *អង្គជំនុំជម្រះ បានសម្រេចរួចហើយ ។ ប្រសិនបើ អ្នកឯងមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ អ្នកឯងអាចប្តឹងសាទុក្ខទៅតាមនីតិវិធីតុលាការ ។ យើងដាច់ខាត មិនឲ្យអ្នកឯងធ្វើអ្វីទៅតាមតែការនឹកឃើញរបស់អ្នកឯងបានទៀតឡើយ។ ឥឡូវនេះ យើងផ្តល់ឲ្យអ្នកឯងសួរសំណួរពាក់ព័ន្ធជាមួយនឹងបរិបទប្រវត្តិសាស្ត្រចំពោះកូនក្តីរបស់អ្នកឯងចាប់ពីពេលនេះតទៅ*[22] ។

ដោយសារមិនរីករាយនឹងការឆ្លើយតបរបស់ប្រធានតុលាការ មេធាវី **ផេស្តមិន** បានសួរទៅកាន់អង្គជំនុំជម្រះថាតើខ្លួនត្រូវបានទទួលការបង្ខំឲ្យដាក់ពាក្យបណ្តឹងនៅពេលនេះទេ ហើយគាត់ក៏បានទទូចផងដែរថា យ៉ាងហោចណាស់ អង្គជំនុំជម្រះគប្បីអនុញ្ញាតឲ្យគាត់ធ្វើការពន្យល់មូលហេតុផ្ទាល់មាត់សិន ថាហេតុអ្វីបានជាក្រុមខ្លួនលើកឡើងពីបញ្ហានេះ ។ ក្នុងអំឡុងនៃពេលពិភាក្សាលើបញ្ហានេះ អង្គជំនុំជម្រះបានព្រមានលោក **ផេស្តមិន** ថាមេធាវីរូបនេះកំពុងតែធ្វើឲ្យបាត់បង់ពេលវេលាក្នុងការតាំងសំណួរលើជនជាប់ចោទ ។ លោក **ផេស្តមិន** បានតស៊ូជំនះរហូតទាល់តែអង្គជំនុំជម្រះសម្រេចប្រកាសថា ពេលវេលារបស់មេធាវីការពារក្តីដែលត្រូវតាំងសំណួរសួរកូនក្តីខ្លួនបានប្រើប្រាស់អស់ហើយ ហើយអង្គជំនុំជម្រះក៏បានផ្តល់វេទិកាបន្តទៅចៅក្រម **ឡាវែន៍** ដើម្បីធ្វើការសួរ

ដេញដោលលើលោក **នួន ជា** ។ អង្គជំនុំជម្រះ បានថ្លែងបន្ថែមទៀតថា ឥរិយាបថរបស់លោក **ផេស្តមិន** គឺបានបង្ហាញពីការមិនគោរពដល់អង្គជំនុំជម្រះ ។

នៅរសៀលថ្ងៃពុធ លោក **ផេស្តមិន** បានព្យាយាមលើកនូវសំណើផ្ទាល់មាត់ស្តីពីការបាត់បង់អស់រយៈពេល៣០នាទី ក្នុងការតាំងសំណួរលើកូនក្តីខ្លួន និងទទូចសុំឲ្យអង្គជំនុំជម្រះផ្តល់ពេលវេលានោះឲ្យគាត់វិញ ។ ប្រធានតុលាការបានថ្លែងថា អង្គជំនុំជម្រះមិនបានដកហូតនូវសិទ្ធិក្នុងការតាំងសំណួររបស់មេធាវី **ផេស្តមិន** ទេ និងថាផ្ទុយទៅវិញ គឺលោកមេធាវីខ្លួនឯងដែលបោះបង់សិទ្ធិរបស់គាត់ដោយខកខានមិនបានប្រើប្រាស់ពេលវេលាដែលបានបែងចែកនោះឲ្យបានត្រឹមត្រូវ ។ លោក **ផេស្តមិន** បានតវ៉ាថា គាត់មិនបានលះបង់សិទ្ធិនៅក្នុងការតាំងសំណួរចំពោះកូនក្តីគាត់នោះទេ ហើយកូនក្តីគាត់ផ្ទាល់ក៏មិនបានលះបង់សិទ្ធិ មិនឆ្លើយតបទៅនឹងសំណួរដែលសួរដោយលោកដែរ ។ ដល់ចំណុចនេះ អង្គជំនុំជម្រះ បានសម្រេចផ្តល់ពេលវេលាដល់លោក **ផេស្តមិន** រយៈពេល៣០នាទី ក្នុងការចោទសួរទៅកាន់កូនក្តីរបស់គាត់ ។

## *ជំពូកទី៤ ៖* ការគ្រប់គ្រងសវនាការ

ការអនុវត្តនីតិវិធីនៅសប្តាហ៍នេះ គឺខុសពីសព្វមួយដង ដោយសារតែអង្គជំនុំជម្រះដែលធ្លាប់តែអនុញ្ញាតឲ្យជនជាប់ចោទចូលរួមតាមដានសវនាការពីចម្ងាយ បែរជាបានសម្រេចទាមទារឲ្យលោក **នួន ជា** ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការ ។ ប៉ុន្តែក្រោយមកលោក **នួន ជា** បានដាក់លិខិតលះបង់សិទ្ធិមានវត្តមានរបស់លោកនៅក្នុងពេលកំពុងដំណើរការនីតិវិធីសវនាការ ។ អង្គជំនុំជម្រះ បានដោះស្រាយនូវបញ្ហាមួយចំនួនដែលបានលើកឡើងដោយភាគីទាំងឡាយ ទាក់ទងនឹងការរៀបចំកាលវិភាគនៃកិច្ចដំណើរការនីតិវិធីសវនាការ និងបានធ្វើការកែសម្រួល ដើម្បីឲ្យឆ្លើយតបទៅនឹងការស្នើសុំទាំងនេះ។

### ក. វត្តមាន

កាលពីថ្ងៃច័ន្ទ និងថ្ងៃព្រហស្បតិ៍ លោក **អៀង សារី** បានចូលរួមតាមដានសវនាការពីបន្ទាប់ឃុំឃាំងខាងក្រោម បន្ទាប់ពីការសម្រាកសវនាការនៅក្នុងវគ្គទី១នៅពេលព្រឹក ។ មុនកិច្ចចាប់ផ្តើមនៃសវនាការកាលពីថ្ងៃពុធ លោក **អៀង សារី** តាមរយៈមេធាវីជាតិរបស់ខ្លួន គឺលោក **អាង ឧត្តម** បានស្នើសុំឲ្យកូនក្តីខ្លួនចូលរួមតាមដានសវនាការពីចម្ងាយជាជាងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ។ អង្គជំនុំជម្រះ បានសម្រេចយល់ព្រមតាមការស្នើសុំទាំងនេះ ។ នៅថ្ងៃច័ន្ទ លោក **នួន ជា** ក៏ត្រូវបានលើកលែងដោយមិនចាំបាច់ចូលរួមដោយផ្ទាល់នៅក្នុងនីតិវិធីសវនាការ បន្ទាប់ពីវគ្គសម្រាកពេលព្រឹក ។ លោក **នួន ជា** បានមានវត្តមានពេញមួយព្រឹកថ្ងៃពុធ ខណៈដែលមិនមានសវនាការនីតិវិធីត្រូវបានធ្វើឡើងឡើយនៅពេលរសៀល ដោយសារតែអង្គជំនុំជម្រះមានការប្រជុំផ្ទៃក្នុងមួយ ។

នៅថ្ងៃព្រហស្បតិ៍ ព្រះរាជអាជ្ញាអន្តរជាតិ **លីសាក់** បានធ្វើការជំទាស់នៅពេលដែលលោកមេធាវីការពារក្តី **ផេស្តមិន** បានធ្វើការស្នើសុំឲ្យកូនក្តីរបស់គាត់ គឺលោក **នួន ជា** ឲ្យចូលរួមតាមដានសវនាការពីចម្ងាយដោយសារ

តែបញ្ហាសុខភាព។ លោក **លីសាក់** បានសង្កត់ធ្ងន់ថា សវនាការលើភស្តុតាង គឺមានសារៈសំខាន់ណាស់សម្រាប់ជនជាប់ចោទ ហេតុដូចនេះ ជនជាប់ចោទគួរតែមានវត្តមាននៅក្នុងបន្ទប់សវនាការ ហើយប្រើប្រាស់ឱកាសនេះ ដើម្បីធ្វើការអត្ថាធិប្បាយ ឬផ្តល់យោបល់លើឯកសារទាំងឡាយដែលដាក់បង្ហាញនៅចំពោះមុខខ្លួន ។ ក្នុងការឆ្លើយតបទៅនឹងការស្នើសុំ និងការជំទាស់នេះ អង្គជំនុំជម្រះ បានសម្រេចមិនអនុញ្ញាតឲ្យលោក **នួន ជា** បោះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ ហើយទៅតាមដានពីបន្ទប់សោតទស្សន៍ខាងក្រោមឡើយ ។ លោក **ខៀវ សំផន** បានមានវត្តមានរាល់ថ្ងៃនៃកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសប្តាហ៍នេះ ។

**ការចូលរួមពីសាធារណជន៖** មានការចូលរួមយ៉ាងច្រើនគួរឲ្យកត់សម្គាល់ពេញមួយសប្តាហ៍នេះ។ នៅថ្ងៃច័ន្ទ មានសិស្សានុសិស្សប្រមាណជា ៣០០នាក់ មកពីវិទ្យាល័យបឹងកេងកងនៃទីក្រុងភ្នំពេញ បានចូលរួមពេញមួយថ្ងៃនៃនីតិវិធីសវនាការ ។ ពេញមួយព្រឹកនៃថ្ងៃពុធវិញ ក៏មានសិស្សានុសិស្សប្រមាណជា ៣០០នាក់ មកពីវិទ្យាល័យព្រះស៊ីសុវត្ថិ នៅទីក្រុងភ្នំពេញ ។ នៅថ្ងៃចុងក្រោយ មានប្រជាពលរដ្ឋប្រមាណជា ៣០០នាក់ បានមកពីខេត្តតាកែវ បូករួមនឹងសិស្សានុសិស្សប្រមាណជា ៥០នាក់ ផ្សេងទៀត ដែលមានអាយុចាប់ពី១៤ ទៅ១៦ឆ្នាំមកពីសាលាអន្តរជាតិ អាយ.អ៊ី.អ៊ែល ភ្នំពេញ បានចូលរួមតាមដានសវនាការនៅពេលព្រឹក ។ ដោយឡែក នៅពេលរសៀល មានសិស្សានុសិស្សប្រមាណជា ៣០០នាក់ មកពីវិទ្យាល័យភ្នំពេញថ្មី បានតាមដានសវនាការនីតិវិធី ។

## ខ. ឥរិយាបថនៅក្នុងបន្ទប់សវនាការ

នៅថ្ងៃពុធ លោកស្រីចៅក្រម **ខាត់រ៉ាយច៍** បានយកឱកាសដោះស្រាយអំពីបញ្ហាសុជីវធម៌នៅក្នុងបន្ទប់សវនាការ បន្ទាប់ពីលោកស្រីបានកត់សម្គាល់ឃើញថា លោកមេធាវី **ផេស្តមិន** មិនបានស្លៀកពាក់ឲ្យបានត្រឹមត្រូវទាន់ពេលនៃកិច្ចចាប់ផ្តើមនីតិវិធីសវនាការ ។ លោកស្រីចៅក្រម បានផ្តល់ការណែនាំដល់មេធាវីរូបនេះ ឲ្យស្លៀកសម្លៀកបំពាក់ឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា មុនពេលសវនាការចាប់ផ្តើម ។ លោកស្រី បានថ្លែងដូចខាងក្រោមនេះ៖

> *លោក **ផេស្តមិន** ថាតើលោកអាចបញ្ជាក់បានទេថា លោកនឹងរៀបចំខ្លួនឲ្យបានស្រេចបាច់មុនពេលចៅក្រមចូលមកដល់? យើងបានទុកឱកាសនេះឲ្យលោកយូរមកហើយ តែលោកដូចជាមិនអាចមកឲ្យទាន់ពេល ដូចជាសហសេវិករបស់លោកសោះ*[23] ។

## គ. ការគ្រប់គ្រងពេលវេលា

ការបកស្រាយបញ្ជាក់នានាទាក់ទងនឹងបញ្ហាកាលវិភាគ ត្រូវបានធ្វើឡើងក្នុងអំឡុងសប្តាហ៍នេះ។ មុនពេលបញ្ចប់នីតិវិធីសវនាការនៅថ្ងៃច័ន្ទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ លោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** (Ms. Elisabeth SIMONNEAU-FORT) បានសួរទាក់ទងនឹងកាលវិភាគសវនាការសម្រាប់ថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ ។ ប្រធានតុលាការ ចៅក្រម **និល ណុន** បានធ្វើការកត់សម្គាល់ថា ការគ្រប់គ្រងបញ្ជីសំណុំរឿង គឺមានភាពស្មុគស្មាញ ក៏ប៉ុន្តែអង្គជំនុំជម្រះនឹងព្យាយាមតាមដែលអាចធ្វើទៅបានដើម្បីជូនដំណឹងជាមុនដល់

ភាគីស្តីពីកាលវិភាគសវនាការនាពេលខាងមុខៗ ។ លោកប្រធាន បានពន្យល់ថា បន្ទាប់ពីការសួរដេញដោលទៅលើលោក **នួន ជា** ហើយអង្គជំនុំជម្រះនឹងពិភាក្សាលើបញ្ហាដែលទាក់ទងនឹងឯកសារ ដែលដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ។ សម្រាប់សប្តាហ៍បន្ទាប់ទៀត តុលាការនឹងនៅតែបន្តនូវដំណើរការនីតិវិធីសវនាការស្តីពីបរិបទនៃប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ និងការទំនាក់ទំនង ។

កាលពីថ្ងៃពុធ ប្រធានអង្គជំនុជម្រះ លោកចៅក្រម **និល ណុន** ប្រកាសថា សវនាការដែលពាក់ព័ន្ធបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាបានដល់ទីបញ្ចប់ហើយ ហើយភាគីគួរតែធ្វើការដាក់បង្ហាញនូវឯកសារនានាចំពោះមុខតុលាការនៅក្នុងថ្ងៃព្រហស្បតិ៍ ។ ការថ្លែងដូចនេះ ហាក់បីដូចជាធ្វើឲ្យភាគីក្នុងបន្ទប់សវនាការមានការភាន់ច្រឡំ។ ជាដំបូង លោក **ផេស្តមិន** បានសួរទៅកាន់អង្គជំនុំជម្រះថាតើនឹងមានអ្វីកើតឡើង បន្ទាប់ពីបានដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះហើយ នៅព្រឹកថ្ងៃព្រហស្បតិ៍ ។ អង្គជំនុំជម្រះ បានពន្យល់ប្រាប់ថា ប្រសិនបើការដាក់បង្ហាញឯកសារមិនអាចធ្វើឡើងនៅចំពោះមុខភាគីនៅពេលព្រឹកនោះទេ ភាគីនឹងអាចបន្តដាក់ឯកសារនៅពេលរសៀល ។ លោកប្រធានអង្គជំនុំជម្រះ បានពន្យល់បន្ថែមថា អង្គជំនុំជម្រះនឹងបន្តនីតិវិធីសវនាការនៃវគ្គទីមួយ ស្តីពីប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជាសម្រាប់រយៈពេលពីរថ្ងៃបន្ថែមទៀត បន្តពីនីតិវិធីសវនាការលើភស្តុតាង និងអង្គហេតុទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល ទំនាក់ទំនង និងប្រព័ន្ធរដ្ឋបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកប្រធាន បានរម្លឹកថា មន្ត្រីច្បាប់បានធ្វើការជូនដំណឹងដល់ភាគីហើយ ស្តីអំពីការរៀបចំកាលវិភាគយ៉ាងណានោះ ហើយការជូនដំណឹងជាផ្លូវការនឹងផ្ញើជូនគ្រប់ភាគីតាមក្រោយ ។ ភ្លាមៗនោះលោកស្រី **ស៊ីម៉ុនណូហ្សត** បានជូនដំណឹងដល់តុលាការថា មន្ត្រីច្បាប់ជាន់ខ្ពស់នៃ **អ.វ.ត.ក** បានផ្ញើរព័ត៌មានដល់អ្នកស្រីតាមរយៈការផ្ញើសារអេឡិចត្រូនិច (អ៊ីម៉ែល) ថា លោកស្រីនឹងត្រូវដាក់បង្ហាញឯកសារនៅសប្តាហ៍បន្ទាប់ ។ លោកស្រីបានថ្លែងថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនអាចរៀបរយក្នុងការដាក់បង្ហាញឯកសារនៅចំពោះមុខភាគីបានទេ នៅថ្ងៃស្អែកនេះ ។ ប្រធានតុលាការ បានទទួលស្គាល់ថាប្រសិនបើភាគីទាំងអស់មិនទាន់រួចរាល់ក្នុងការដាក់បង្ហាញឯកសារទេ ពួកគេអាចធ្វើការដាក់បង្ហាញនៅអំឡុងពេលពីរថ្ងៃដំបូងនៃកាលវិភាគសវនាការនាសម្រាប់សប្តាហ៍ក្រោយ ។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | ការសម្រាក ពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ០៦/០២/១២ | ៩:០១ | ១០:៣៣-១០:៥១ | ១២:០៤-១៣:៣៥ | ១៥:04 | ១៥:០៤ | ៤ម៉ោង និង២៤នាទី |
| ថ្ងៃអង្គារ ០៧/០២/១២ | - | - | - | - | - | - |
| ថ្ងៃពុធ ០៨/០២/១២ | ៩:០១ | ១០:៣១-១០:៥៣ | ១២:០០ | - | ១២:០០ | ២ម៉ោង និង៣៧នាទី |
| ថ្ងៃព្រហស្បតិ៍ ០៩/០២/១២ | ៩:០៣ | ១០:៥៤-១០:៥៤ | ១១:៥៤-១៣:៣៤ | ១៤:៤៩ | ១៤:៤៩ | ៣ម៉ោង និង៤៦នាទី |
| *ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ៖ ៣ម៉ោងនិង៣៥នាទី*<br>*ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ ៖ ១០ម៉ោង និង៤៧នាទី*<br>*ចំនួនសរុបនៃ ម៉ោង ថ្ងៃ និងសប្តាហ៍៖ ១១៩ម៉ោង និង៥១នាទី* | | | | | | |
| ***រយៈពេលសវនាការចំនួន ២៨ថ្ងៃ អំឡុងពេល ៨សប្តាហ៍*** | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of NuonChea, IengSary, IengThirith and KhieuSamphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of KaingGuekEav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of NuonChea, IengSary, IengThirith and KhieuSamphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

*AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes, Adair Fincher, Nora Fuchs, Princess B. Principe, SovannaSek, ChayanichThamparipattra and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR report on Crimes Studies Center.

[1] Trial Chamber. Transcript of Trial Day 29 (9 February 2012), Case No. 002/19-09-2007. [Hereinafter, 9 FEBRUARY TRANSCRIPT]. E1/41.1 Lines 20-22.43

[2] “According to the NuonCheaDefence, journalist quoted Cambodia’s Prime Minister at a press conference in Vietnam, dwcribing statements NuonChea gave to the Court in December as ‘Deceitful.’ With much indignation, Pestman further pointed out that the Prime Minister had also recently been quoted calling NuonChea a ‘killer’ and a ‘perpetrator of genocide.’ Case 002 KRT TRIAL MONITOR ISSUES NO. 08 (week ending 12 january 2012). 10

[3] HengSamrin “became the leader of the United Front for the National Salvation of Kampuchea, head of state, leader of the Khmer People’s Revolutionary Party, senior privy councilor [sic] to the king and ultimately president of the National Assembly.” Luke Hunt, “HengSamrin, Man of the People,” *The Diplomat,* 21 September 2011, <http://thediplomat.com/asean-beat/2011/09/21/heng-samrin-man-of-the-people/>, accessed on 16 July 2012.

[4] Trial Chamber. Transcript of Trial Day 27 (6 February 2012), Case No. 002/19-09-2007. E1/39.1. [Hereinafter, 6 FEBRUARY TRANSCRIPT].Line 7, 5.

[5] 6 FEBRAURY TRANSCRIPT. Line 4-5, 16.

[6] Trial Chamber. Transcript of Trial Day 21 (25 January 2012), Case No. 002/19-19-2007. E1/33.1. Lines 21-24, 32.

[7] 6 FEBRAURY TRANSCRIPT. Lines 14-16, 46.

[8] Ibid, lines 12-15, 47.

[9] Ibid, lines 21-22, 46.

[10] Ibid, line 15-17, 68.

[11] Ibid, lines 19-25; 1-5. 68-69.

[12] 9 FEBRUARY TRANSCRIPT. Lines 19. 43.

[13] Ibid, lines 11-12. 41.

[14] Ibid, lines 19-22. 41.

[15] See Trial Chamber. Transcript of Trial Day 28 (8 February 2012), Case No. 002/19-09-2007. [Hereinafter, 8 FEBRUARY TRANSCRIPT]. E1/40. Lines 2-8. 38.

[16] 1. Summary of the revolutionary movement and the CPK, including the CPK philosophy and the CPK’s method for achieving scocialism; 2. Record of Mr. IengSary’s interview conducted on 10 November 2007 before the Co-Investigating Judges; 3. Biography of IengSary; 4. Record of PhanSovannhan’s interview before the Co-Investigating Judge; 5. A book written by KhieuSamphan on the History of Kampuchea; 6. Copy of the “Revolutionary Flag;” 7. The Circular of the Democratic Kampuchea; 8. IengSary’s interview by Elizabeth Becker, 9. “Brief Summary of the Party’s History,” 10. Record of IengSary’s 12 November 2007 interview befoe the Co-Investigating Judges; 11. Statement by Duch; 12. Record of interview of Witness PhyPhoun in BanteayMeanchey by the Co-Investigating Judges; 13. Record of meeting of secretaries and under-secretaries and under-secretaries of the special independent divisions in 1976; 14. Record of an interview of NuonChea and KhemNgun; 15. Record of an interview of IengSary with ABC TV Australia; 16. “When the War Was Over,” by Elizebeth Becker; and 17. Central Committee of CPK Directive, “Decision of the Central Committee Regarding Certain matters,” dated 30 march 1971.

[17] The Facts agreed on by the OCP and the IengSary team are in the following paragraphs of the Closing paragraph 27, paragraph 33, paragraph 35, paragraph 42, paragraph 995, paragraph 996, paragraph 997, paragraph 998, paragraph 999, and paragraph 1000.

[18] 9 FEBRAURY TRANSCRIPT. Lines 12-20. 6.

[19] Ibid, lines 10-13. 65

[20] 6 FEBRAURY TRANSCRIPT. Lines 21-25; 2-4. 75-76.

[21] Pauw asked about DC-Cam’s access to CPP archives, to which the OCP objected. Pauw argued that the OCP could ask about access to the Ministry of the Interior and the National Archive and his question should not be treated differently. The President did not sustain the object.

[22] 8 FEBRUARY TRANSCRIPT. Lines 16-25; 1. 4-5.

[23] Ibid, lines 19-22. 32.